# ផែនការសកម្មភាពរបស់សហប្រជាជាតិ ស្តីពីសុវត្ថិភាពរបស់អ្នកសារព័ត៌មាន និង បញ្ហានិទណ្ឌភាព




United Nations Educational, Scientific and Cultural Organization

UN Plan of Action on the Safety of Journalists and the Issue of Impunity

ផែនការសកម្មភាព របស់សហប្រជាជាតិស្តីពីសុវត្ថិភាពរបស់អ្នកសារព័ត៌មាន និងបញ្ហានិទណ្ឌភាពនេះ មានគោលបំណងខិតខំបង្កើតឱ្យមាន

## បរិយាកាសមួយ ដើម្បីឱ្យអ្នកសារព័ត៌មាន និង បុគ្គលិករបស់ប្រព័ន្ធផ្សព្វផ្សាយ មានសេរីភាពនិងសុវត្ថិភាព ទាំងនៅក្នុងស្ថានភាពមានវិវាទ និងស្ថានភាពដែលគ្មានវិវាទ

ក្នុងទិសដៅពង្រឹងសន្តិភាព លទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍនៅទូទាំងសកលលោក។

ផែនការសកម្មភាពរបស់សហប្រជាជាតិនេះ គឺជាគំនិតផ្តួចផ្តើមថ្មីមួយ នៅក្នុងក្របខ័ណ្ឌសហប្រជាជាតិទាំងមូល ដោយមានការសម្របសម្រួល ពីអង្គការយូណេស្កូ ដើម្បីផ្តល់នូវក្របខ័ណ្ឌរួមមួយ សម្រាប់ឱ្យប្រព័ន្ធសហប្រជាជាតិ ធ្វើការងាររួមគ្នាជាមួយនឹងគ្រប់ អ្នកពាក់ព័ន្ធទាំងអស់ដូចជា អាជ្ញាធរជាតិ និងអង្គការនានា នៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ សំដៅបង្កើតនូវបរិយាកាសមួយ ប្រកបដោយសុវត្ថិភាពសម្រាប់អ្នកសារព័ត៌មាន បុគ្គលិករបស់ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកផលិតព័ត៌មាន តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម និងធ្វើការប្រយុទ្ធប្រឆាំង នឹងនិទណ្ឌភាពសម្រាប់បទឧក្រិដ្ឋប្រឆាំងនឹងពួកគេ។

ផែនការសកម្មភាពរបស់សហប្រជាជាតិនេះ គឺជាលទ្ធផលនៃកិច្ចពិគ្រោះយោបល់ទូលំទូលាយនៅទូទាំងពិភពលោក រួមជាមួយនឹងរដ្ឋជាសមាជិក ប្រព័ន្ធផ្សព្វផ្សាយ សមាគមវិជ្ជាជីវៈ និងអង្គការក្រៅរដ្ឋាភិបាល។



ផែនការរបស់សហប្រជាជាតិនេះ គឺជាកាលានុវត្តភាពជាប្រវត្តិសាស្ត្រមួយ ដើម្បីបង្កើតឱ្យមានភាពខុសប្លែកគ្នាមួយ ចំពោះសុវត្ថិភាពរបស់អ្នកសារព័ត៌មាន និងសេរីភាពក្នុងការបញ្ចេញមតិយោបល់នៅក្នុងសង្គម។

បុគ្គល និងស្ថាប័ននានា អាចធ្វើសកម្មភាពជាច្រើន ដើម្បីបំពេញបន្ថែមលើផែនការរបស់សហប្រជាជាតិនេះ តាមរយៈការបង្កើនសម្លេង និងសកម្មភាពរបស់ពួកគេ ដើម្បីសុវត្ថិភាពរបស់អ្នកសារព័ត៌មាន។ ឥទ្ធិពលរួមនៃសកម្មភាពនេះ នឹងជួយញុំនាំវប្បធម៌សន្តិភាពឱ្យមកកាន់តែកៀកនឹងពិភពលោក ដែលមនុស្សគ្រប់រូបមានសុវត្ថិភាពនិយាយដោយគ្មានការភ័យខ្លាច និងដែលពុំមានអ្នកណាម្នាក់ត្រូវបានគេហាមឃាត់មិនឱ្យមានឱកាសស្តាប់ លើការផ្តល់សក្ខីកម្មរបស់អ្នកដទៃទៀត។

**www.unesco.org/webworld/en/UN-plan-safety**

United Nations Educational, Scientific and Cultural Organization

UN Plan of Action on the Safety of Journalists and the Issue of Impunity

សូមទំនាក់ទំនង: Sylvie Coudray. *s.coudray@unesco.org*
*ប្រធានផ្នែកសេរីភាពក្នុងការបញ្ចេញមតិយោបល់ នៅក្នុងផ្នែកប្រាស្រ័យទាក់ទង និងព័ត៌មាន*

មានអ្នកសារព័ត៌មាន បុគ្គលិកប្រព័ន្ធផ្សព្វផ្សាយ និងអ្នកផលិតព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយសង្គជាង ៦០០នាក់ ត្រូវបានគេសម្លាប់នៅក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ។

## អ្នកសារព័ត៌មាន ដែលត្រូវបានគេបំបិទមាត់ ធ្វើឱ្យសម្លេងរបស់ប្រជាពលរដ្ឋលែងឮ និងរាំងខ្ទប់សិទ្ធិដឹងឮរបស់ពួកគេ ។

នៅពេលដែលអ្នកសារព័ត៌មានម្នាក់ត្រូវបាគេធ្វើឃាត សាររន្ធត់មួយត្រូវបានបញ្ជូនទៅកាន់សាធារណជន៖ "សូមកត់ចំណាំទុក មិនគួរមានអ្នកណាម្នាក់និយាយចេញទៅក្រៅឡើយ នៅពេលដែលមានរឿងមិនល្អកើតមានឡើង"។

ការធ្វើឃាតអ្នកសារព័ត៌មាន មិនត្រឹមតែលុបបំបាត់យ៉ាងសាហាវព្រៃផ្សៃនូវសិទ្ធិមានសេរីភាពបញ្ចេញមតិ យោបល់របស់អ្នកសារព័ត៌មានជាបុគ្គលនោះទេ ប៉ុន្តែវាក៏ជាសញ្ញាខ្ទប់មិនឱ្យប្រជាពលរដ្ឋមានសិទ្ធដូចគ្នានេះផងដែរ។ ជាលទ្ធផល សង្គមមិនអាចធ្វើសេចក្តីសម្រេចចិត្តផ្អែកលើព័ត៌មានបាន ហើយប្រជាពលរដ្ឋដែលមានការភ័យខ្លាចបង្ខំចិត្តឃាត់ឃាំងខ្លួនឯងមិនឱ្យនិយាយ។

ដើម្បីបញ្ចប់អំពើហិង្សាលើអ្នកសារព័ត៌មាន សហប្រជាជាតិបានបង្កើត

## ផែនការសកម្មភាពរបស់សហប្រជាជាតិអំពីសុវត្ថិភាពអ្នកសារព័ត៌មាន និងបញ្ហានិទណ្ឌភាព

## ជារឿងរាល់សប្តាហ៍

### អ្នកសារព័ត៌មានម្នាក់បាត់បង់អាយុជីវិតរបស់ខ្លួន ដោយសារតែបានពាំនាំយកដំណឹង និងព័ត៌មានដល់មនុស្សទូទៅ

ផែនការសកម្មភាពរបស់សហប្រជាជាតិ ប្រើប្រាស់ប្រព័ន្ធសហប្រជាជាតិទាំងមូល ដើម្បីបង្កើតនូវកម្មវិធីមួយដែលមានការសម្របសម្រួលបានល្អ ប្រកបដោយសុខុដុមនីយកម្ម ដើម្បីបញ្ឈប់ការសម្លាប់អ្នកសារព័ត៌មាន។ គោលដៅនេះអាចសម្រេចបាន តាមរយៈការសហការយ៉ាងជិតស្និទជាមួយនឹងរដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយ ក្រុមវិជ្ជាជីវៈ និងសង្គមស៊ីវិល។ កម្មវិធីនេះគាំទ្រដល់រដ្ឋាភិបាល នៅក្នុងការបង្កើតច្បាប់ស្តីពីការការពារ សុវត្ថិភាពរបស់អ្នកសារព័ត៌មាន និងបំពេញតួនាទីឱ្យបានសកម្ម នៅក្នុងការបង្ការមិនឱ្យមានការវាយប្រហារ និងការគំរាមកំហែងនានា។ កម្មវិធីនេះលើកកម្ពស់ការយល់ដឹង នៅក្នុងសង្គមទាំងមូល ដើម្បីឱ្យប្រជាពលរដ្ឋ អាចយល់ពីផលប៉ះពាល់ជាអវិជ្ជមានជាច្រើន នៅពេលដែលសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិយោបល់របស់ អ្នកសារព័ត៌មានត្រូវបានគេរឹតត្បិត ឬលុបបំបាត់។

### ជនរងគ្រោះភាគច្រើន គឺជាបុគ្គលិករបស់ប្រព័ន្ធផ្សព្វផ្សាយនៅក្នុងប្រទេស ដែលរាយការណ៍អំពី

## រឿងរ៉ាវនៅក្នុងស្រុក

ខណៈពេលដែលសកម្មភាពនៅក្នុងផែនការរបស់ សហប្រជាជាតិនេះមានមួយផ្នែកស្ថិតនៅកម្រិតសកលក៏មានសកម្មភាពពិសេសៗនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិដែល ជាកន្លែងផ្តោតការយកចិត្តទុកដាក់ លើការអនុវត្តតាមរយៈការខិតខំប្រឹងប្រែងរួមគ្នារបស់ទីភ្នាក់ងារសហប្រជាជាតិ នៅក្នុងក្រុមការងារប្រចាំប្រទេស និងតាមរយៈការលើកកម្ពស់ឱ្យមានការតម្រឹមឱ្យស្របគ្នានូវសកម្មភាព ដែលអនុវត្តដោយគ្រប់អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងដែនដីនោះ។

## នៅក្នុងករណីភាគច្រើន អ្នកសារព័ត៌មានដែលត្រូវបានគេធ្វើឃាត គឺជាអ្នកដែលរាយការណ៍ពីអំពើពុករលួយ និងសកម្មភាពខុសច្បាប់ដទៃទៀតដូចជា បទឧក្រិដ្ឋ ដែលមានអង្គការចាត់តាំងជាដើម

ផែនការរបស់សហប្រជាជាតិនេះ គឺជាផ្នែកមួយនៃការបំពេញការងាររបស់ទីភ្នាក់ងារសហប្រជាជាតិ ដើម្បីគាំទ្រដល់ប្រទេសទាំងឡាយ ដែលខិតខំទប់ស្កាត់អំពើពុករលួយ។ នៅពេលដែលអ្នកសារព័ត៌មានមានសុវត្ថិភាព ក្នុងការបង្ហាញឱ្យឃើញពីការ គេបន្លំ និង ការកិបកេងថវិកាសង្គមទូទៅនឹងកាន់តែមាន លទ្ធភាពប្រយុទ្ធប្រឆាំង នឹងឧបសគ្គដ៏ចម្បង □ ដែលបន្ទុចបង្អាក់ ដល់ការអភិវឌ្ឍមួយនេះ។



## មានភ័ស្តុតាងដែលបង្ហាញថា នៅក្នុងករណីភាគច្រើន អ្នកសារព័ត៌មានទទួលបានការគំរាមកំហែង មុនពេលត្រូវបានគេសម្លាប់

ផែនការរបស់សហប្រជាជាតិនេះ លើកកម្ពស់យន្តការបង្ការ និងស្តង់ដានានាដូចជា ធ្វើការផ្សព្វផ្សាយការអនុវត្តល្អៗ ដែលទទួលបានពីប្រទេសនានា ដែលរដ្ឋាភិបាលបានទទួលជោគជ័យ ក្នុងការផ្តល់នូវការការពារទាន់ពេលវេលា និងមានប្រសិទ្ធភាព។ ផែនការនេះក៏មានដាក់បញ្ចូលនូវជំហាននានាដើម្បីគាំទ្រដល់ការពិនិត្យតាមដានសុវត្ថិភាពរបស់អ្នកសារព័ត៌មាន ដូចជាការចែករំលែកនូវព័ត៌មានបច្ចុប្បន្នភាព នៅក្នុងចំណោមគ្រប់អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងវិស័យនេះ។

## មានករណីធ្វើឃាត អ្នកសារព័ត៌មានជាង៩០% ដែលគ្មានការដាក់ទោសទណ្ឌ

នៅពេលដែលអ្នកសារព័ត៌មានត្រូវបានគេធ្វើឃាត ដោយមិនទទួលរងការដាក់ទោសទណ្ឌ អ្វីទាំងអស់ ជនប្រព្រឹត្តនឹងកាន់តែមានសេចក្តីក្លាហានកាន់តែខ្លាំងឡើង ដើម្បីប្រព្រឹត្តអំពើនេះបន្ថែមទៀត។ នីតិរដ្ឋដែលមានន័យថា មិនគួរមានអ្នកណាម្នាក់គួរទទួលបាននិទណ្ឌភាពរួចផុតពីបទឧក្រិដ្ឋ ដែលពួកគេប្រព្រឹត្តឡើយ គឺជាទិដ្ឋភាពដ៏សំខាន់មួយនៃផែនការរបស់សហប្រជាជាតិនេះ។ មានការអំពាវនាវឱ្យរដ្ឋាភិបាលនានាអនុលោមទៅតាមសេចក្តីសម្រេចអន្តរជាតិ និងធានា យ៉ាងណាឱ្យមានដំណើរការក្នុងប្រព័ន្ធតុលាការ ពេញលេញ ជាការឆ្លើយតបចំពោះករណីធ្វើឃាតអ្នកសារព័ត៌មាន។ ផែនការនេះផ្តល់នូវជំនួយពីសហប្រជាជាតិ ដើម្បីពង្រឹងការស៊ើបអង្កេតរបស់ប៉ូលីស និងដំណើរការកាត់ក្តីនៅតុលាការ ហើយបានធ្វើការបញ្ជាក់ថា ពុំមានអាជ្ញាយុកាលសម្រាប់ជនដែលមានទោសប្រព្រឹត្តបទឧក្រិដ្ឋចំពោះសេរីភាពនៃការបញ្ចេញមតិយោបល់ឡើយ។







### ការវាយប្រហារលើអ្នកដែលមានវិជ្ជាជីវៈសារព័ត៌មាន ក៏រាប់បញ្ចូលផងដែរនូវការចាប់ពង្រត់ ការចាប់ធ្វើជាចំណាប់ខ្មាំង ការបៀតបៀន **ការគំរាមកំហែង** និងការចាប់ខ្លួនដោយខុសច្បាប់ ។ល។

ផែនការរបស់សហប្រជាជាតិនេះ ជម្រុញឱ្យមានការផ្តល់សុវត្ថិភាពដល់អ្នកសារព័ត៌មាន ដូចជា វគ្គបណ្តុះបណ្តាលអំពីសុវត្ថិភាព និងសន្តិសុខតាមរយៈប្រព័ន្ធអេឡិកត្រូនិក ការមានការធានារ៉ាប់រងសុខភាព និងអាយុជីវិត និងយន្តការឆ្លើយតបចំពោះករណីអាសន្នជាក់ស្តែង។ ផែនការនេះក៏ខិតខំពង្រឹងសុវត្ថិភាពរបស់អ្នកសារព័ត៌មាន នៅក្នុងតំបន់មានជម្លោះ ដកចេញពីបទព្រហ្មទណ្ឌនូវបទល្មើសបរិហារកេរ្តិ៍ និងលើកទឹកចិត្ត ឱ្យមានការផ្តល់នូវប្រាក់កម្រៃឱ្យបានគ្រប់គ្រាន់ ដល់ទាំងនិយោជិតធ្វើការពេញម៉ោង និងនិយោជិតឯករាជ្យ។

## អ្នកសារព័ត៌មានជាស្ត្រី កំពុងកាន់តែក្លាយជា ជនរងគ្រោះដោយសារការបៀតបៀនផ្លូវភេទ និងការរំលោភសេពសន្ថវៈ

ឧក្រិដ្ឋជនជាច្រើននាក់ ដែលធ្វើបាបអ្នកសារព័ត៌មានកាន់តែកាចសាហាវ នៅពេលដែលអ្នកសារព័ត៌មានជាមុខសញ្ញារបស់ពួកគេគឺជាស្រ្តី។ ផែនការរបស់សហប្រជាជាតិនេះ ប្រើប្រាស់គោលវិធី ដែលគិតគូរពីយេនឌ័រ ហើយមានដាក់បញ្ចូលនូវសកម្មភាពជាក់លាក់សម្រាប់អ្នកសារព័ត៌មានជាស្ត្រី។

* ព័ត៌មាន និងរូបភាពនានាត្រូវបានយកចេញពីរបាយការណ៍របស់អគ្គនាយកយូណេស្កូ ស្តីពីសុវត្ថិភាពរបស់អ្នកសារព័ត៌មាន និងគ្រោះថ្នាក់របស់និទណ្ឌភាព និងផែនការសកម្មភាពរបស់សហប្រជាជាតិស្តីពីសុវត្ថិភាពរបស់អ្នកសារព័ត៌មាន និងបញ្ហានិទណ្ឌភាព។